# ការស្រាវជ្រាវអង្កេតរកព័ត៌មាន (IAS)

តើការស្រាវជ្រាវអង្កេតរកព័ត៌មានគឺជាអ្វី?



ការស្រាវជ្រាវអង្កេតរកព័ត៌មានគឺជាឧបករណ៍សម្រាប់ :

- បង្ហាញនូវបញ្ហាជាគន្លឹះរបស់មនុស្ស និងព័ត៌មានអ្វីខ្លះដែលពួកគេត្រូវការ
- បង្ហាញនូវប្រភពព័ត៌មានដែលអាចទទួលបាន យុទ្ធវិធីមួយចំនួនដែលពួកគាត់ប្រើដើម្បីទទួលព័ត៌មាន និងបង្ហាញឱ្យឃើញនូវប្រសិទ្ធភាពដ៏មានតម្លៃរបស់ព័ត៌មានទាំងនោះ
- ផ្តល់នូវអនុសាសន៍ពីវិធីសាស្ត្រនៃការទំនាក់ទំនងដែលមានប្រយោជន៍ដល់សហគមន៍ក្រីក្រនៅតាមជនបទដែលប្រើប្រាស់ប្រភពធនធានវារិជាតិសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់



តើព័ត៌មានសម្រាប់ធ្វើអ្វី? តើយើងត្រូវប្រើប្រាស់វាដោយរបៀបណា?

ការស្រាវជ្រាវអង្កេតព័ត៌មានបង្ហាញប្រាប់ពីរបៀបទទួលព័ត៌មានដែលយើងត្រូវការ ។ វាក៏បង្ហាញប្រាប់ឱ្យយើងបានដឹងពីរបៀបដែលធ្វើឱ្យយើងអាចទំនាក់ទំនងបានយ៉ាងល្អប្រសើរជាមួយអ្នកពាក់ព័ន្ធទាំងឡាយ ។ ទាំងនេះគឺជាឧទាហរណ៍បង្ហាញប្រាប់នូវអ្វីដែលធ្វើឱ្យយើងអាចស្វែងរកបាននូវព័ត៌មាននៅពេលណាដែលយើងធ្វើការស្រាវជ្រាវអង្កេតរកនោះ ។

**ត្រូវយកចិត្តទុកដាក់ចំពោះពណ៌ អក្សរ និងភាសាងាយស្រួលយល់ រូបភាពច្បាស់ និងពោរពេញទៅដោយបដិរូប។ ទាំងអស់នេះសុទ្ធតែជាកត្តាចាំបាច់បំផុត។**

**វិទ្យុគឺជាឧបករណ៍ដ៏មានប្រជាប្រិយភាព និងងាយទទួលបានសម្រាប់សហគមន៍ជនជាតិហ្វីលីពីនដែលរស់នៅតាមតំបន់ឆ្នេរ។**

**នៅប្រទេសវៀតណាម សហគមន៍ដាច់ស្រយាលប្រមាណ ៥០០០ ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃនូវប្រព័ន្ធផ្សព្វផ្សាយតាមវិទ្យុ និងដំណឹងតាមប្រដាប់បំពងសម្លេងជាសាធារណៈ ។**

ប្រជាជនរស់នៅតាមសហគមន៍ជនបទរួមមាន ប្រធានភូមិ ព្រះសង្ឃរាជ និងចាស់ព្រឹទ្ធាចារ្យ ជឿជាក់ទៅលើប្រភពព័ត៌មានដែលជាប្រពៃណី។

**នៅប្រទេសកម្ពុជា ល្ខោន និងឆាកកំប្លែងគឺជាល្បែងកំសាន្តដ៏មានប្រជាប្រិយភាព។ មនុស្សជាច្រើនមានជំនឿថា ល្ខោន អាយ៉ៃ យីកេ ដែលលេងតាមវិទ្យុ និងទូរទស្សន៍ គឺទាក់ទាញចំណាប់អារម្មណ៍មហាជនយ៉ាងខ្លាំង ប្រៀបដូចជាយាន្តសម្រាប់ទំនាក់ទំនងព័ត៌មានដូច្នោះដែរ។**

**ជនជាតិវៀតណាមចូលចិត្តអានព័ត៌មាន។**

# ការស្រាវជ្រាវអង្កេតរកព័ត៌មានៈ កំពុងតែចាប់ផ្ដើម



ឆាកកំប្លែងរបស់ជនជាតិហ្វីលីពីន (រឿងស្នេហាដែលមានអត្ថន័យងាយយល់ និងមានរូបភាពគំនូរជីវចលព័ណ៌) គឺមានប្រជាប្រិយភាពណាស់ ។

យើងអាចប្រើប្រាស់មធ្យោបាយតាមគ្រប់រូបភាព។ ក្នុងបរិបទនៃការងារអភិវឌ្ឍន៍ ការស្រាវជ្រាវអង្កេតរកព័ត៌មាន (IAS) អាចត្រូវបានគេប្រើប្រាស់ដើម្បីស្វែងរកនូវព័ត៌មានដែលត្រូវការបន្ថែមទៀតពីសហគមន៍ក្រីក្រនៅតាមជនបទ ។

ការស្រាវជ្រាវអង្កេតរកព័ត៌មាន គឺមានសារសំខាន់ដល់ការធ្វើផែនការគម្រោង ឬការធ្វើអន្តរាគមន៍ ។

ការស្រាវជ្រាវអង្កេតរកព័ត៌មានគប្បី :

- ពិចារណានូវរាល់សេចក្ដីត្រូវការរបស់ក្រុម
- មានការចូលរួមច្រើនកុះករ
- មានការទទួលយកពីសង្គម និងវប្បធម៌
- វិវឌ្ឍន៍តាមសភាពការណ៍ ដើម្បីអោយយើងអាចប្រើប្រាស់ព័ត៌មានទាំងនោះត្រូវតាមសភាពការណ៍
- ផ្ដល់ជាអនុសាសន៍ងាយស្រួលក្នុងការអនុវត្ត

នៅពេលដែលយើងធ្វើការស្រាវជ្រាវអង្កេតរកព័ត៌មាន យើងត្រូវធ្វើឡើងជាក្រុម និងមានទិសដៅទៅមុខជានិច្ច។

ផ្ដើមដោយការសួរជាសំនួរ :

ហេតុអ្វីបានជាយើងស្វែងរកវា ហើយតើយើងចង់បានវាដើម្បីធ្វើអ្វី?

តើយើងទទួលព័តិមានដែលយើងត្រូវការបានយ៉ាងដូចម្ដេច ? តើវីធីណាដែលយើងត្រូវប្រើ?

តើអ្នកណាដែលយើងនឹងត្រូវធ្វើការជាមួយ? តើយើងនឹងត្រូវនិយាយជាមួយគាត់ពីអ្វីដែលយើងចង់បានឬ?

ថាតើអ្នកណានឹងត្រូវធ្វើអ្វី ហើយនៅពេលណា ?



តើយើងនឹងត្រូវប្រាប់គាត់ពីអ្វីដែលយើងស្វែងរកឬ?

តើយើងនឹងត្រូវធ្វើឱ្យកាន់តែប្រសើរអ្វីខះសម្រាប់ពេលបន្ទាប់ ។

តើយើងពិគ្រោះ និងទទួលយកនូវការរីះគន់ស្ថាបនាពីមនុស្សដែលបានជួយយើងដោយរបៀបណា?

តើពេលវេលាប៉ុន្មានដែលយើងមាន? តើវាត្រូវការពេលវេលាប៉ុណ្ណា?

## ការបង្កើតនូវការស្រាវជ្រាវអង្កេតរកព័ត៌មាន : ជាដំណើរការ



**ដូច្នេះបើខ្ញុំចង់បង្កើតនូវការស្រាវជ្រាវអង្កេតរកព័តិមាន តើជំហានអ្វីខ្លះដែលខ្ញុំត្រូវធ្វើ?**



**ចាប់ផ្តើមពីទីនេះ**

### ជំហានទី ១

**សួរពីអ្វីដែលពាក់ព័ន្ធទៅនឹងស្ថានភាពភូមិសាស្ត្រនៃការស្រាវជ្រាវអង្កេតរកព័តិមាន**

- តើចំនួនប្រជាជនសរុបមានប៉ុន្មាននាក់?
- តើអ្នកចេះអក្សរត្រឹមកំរិតណា?
- ភាសាផ្លូវការ ភាសានិយាយ ក្រុមនៃជនជាតិភាគតិច សហគមន៍ជនបទ និងទីក្រុង បុរស និងស្ត្រី?



### ជំហានទី ២

**ស្វែងយល់ពីសហគមន៍ និងបណ្តាញការងារដែលមានស្រាប់**

- តើមានបណ្តាញការងារអ្វីខ្លះ (ផ្លូវការ ឬមិនផ្លូវការ) ?
- តើតាមក្រុមគ្រួសារនីមួយមានវិទ្យុ និងទូទស្សន៍ជាកម្មសិទ្ធដែរឬទេ? (ឬប្រើរួមគ្នា ឬប្រើជាមួយមិត្រភ័ក្ត្រ ឬប្រើជាគ្រួសារ)
- តើអ្នកផ្សព្វផ្សាយពីប្រធានបទអ្វី? - តើមាននរណាខ្លះដែលពេញចិត្តទៅនឹងព័តិមានទាំងនោះ?
- តើមានទស្សនាវត្តី និងសាព័តិមានជាតិ និងក្នុងស្រុកអ្វីខ្លះ? - តើមានអ្នកជំនាញណាខ្លះដែលចាប់អារម្មណ៍នឹងការបោះពុម្ពទាំងអស់នោះ?
- តើការសម្តែងសិល្បៈយ៉ាងដូចម្តេចដែរ? - ការសម្តែងតាមដងផ្លូវ ការសម្តែងតុក្កតា របាំ ការច្រៀងរាំ?



### ជំហានទី ៣

**ស្វែងយល់ពីហេតុផល និងអ្វីដែលនាំឱ្យការងារដំណើរការបានល្អ**

- តើបច្ចុប្បន្ននេះ គ្រប់ស្ថាប័នប្រាស្រ័យទាក់ទងគ្នាយ៉ាងដូចម្តេចដែរ?
- តើរាល់ព័តិមានបានជ្រួតជ្រាបគ្រប់ទីកន្លែងដែរឬទេ? - តើអ្វីខ្លះគួរកែលំអបន្ថែមទៀត?
- តើទំនាក់ទំនងគ្នារវាងស្ថាប័ន និងស្ថាប័នយ៉ាងដូចម្តេចដែរ? (រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការមហាជន សហគមន៍)
- តើមានផែនការ និងយុទ្ធសាស្ត្រយ៉ាងណាដែរ?
- តើវិស័យស្រាវជ្រាវមានដំណើរការយ៉ាងដូចម្តេច តើការទទួលបានព័តិមានថ្មីរបស់ប្រជាជនបានយ៉ាងដូចម្តេចដែរ និងថាតើនរណាអាចប្រើប្រាស់ព័តិមានទាំងនោះ?



### ជំហានទី ៤

**ស្វែងយល់ថាតើប្រជាជនពេញចិត្តទទួលយកព័តិមានរបៀបណា**

- តើប្រជាជនដែលរស់នៅក្នុងភូមិពេញចិត្តទទួលយកព័តិមានរបៀបណា?
- តើប្រភពព័តិមានណាខ្លះដែលគាត់យកទៅប្រើប្រាស់ ចង់បាន ឬជឿជាក់?

### ជំហានទី ៥

**អ្វីដែលជាតម្រូវការ**

- តើការទំនាក់ទំនងណាខះដែលមិនទាន់ត្រូវបានបំពេញ?
- តើអ្វីខ្លះដែលយើងត្រូវការ? ការបណ្តុះបណ្តាល ព័តិមាន ការប្រាស្រ័យទាក់ទងល្អ?

**តើមធ្យោបាយណាខ្លះតម្បីដែលយើងត្រូវប្រើ?**

នៅពេលដែលយើងនិយាយអំពីមធ្យោបាយសម្រាប់ការស្រាវជ្រាវអង្កេតរកព័តិមាន យើងត្រូវនិយាយអំពីបច្ចេកទេសដែលយើងនឹងត្រូវប្រើសម្រាប់ទទួលព័តិមានដែល ចង់បាន ។ ឧទាហរណ៍ដូចជា :

## ការស្វែងរកព័ត៌មាន : ការប្រជុំ




## អាស័យដ្ឋានទំនាក់ទំនងសំខាន់ៗ

### គោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរផ្សេងៗទៀត

មានគោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរផ្សេងៗទៀត រួមមាន :

- ការកសាងមតិឯកភាពគ្នាជារួម
- ក្រុមជួយដោយខ្លួនឯង

លោកអ្នកអាចទទួលបានឯកសារទាំងអស់នេះ និងឯកសារគោលការណ៍ណែនាំអនុវត្តឱ្យកាន់តែប្រសើរផ្សេងទៀតពីការិយាល័យ STREAM នៅតាមប្រទេសរបស់អស់លោកអ្នក ពីការិយាល័យ STREAM ប្រចាំតំបន់ ឬពីគេហទំព័ររបស់ STREAM ។

យើងខ្ញុំសូមទទួលយកនូវរាល់ការរិះគន់ស្ថាបនាពីអស់លោកអ្នក នូវរាល់គោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរ ។

អស់លោកអ្នកអាចផ្តល់នូវការរិះគន់ទាំងនោះតាមរយៈទូរស័ព្ទ អ៊ីមែល ឬសរសេរមកកាន់នាយកទំនាក់ទំនង ដែលប្រចាំការនៅតាមការិយាល័យ STREAM ប្រចាំការតាមប្រទេសរបស់អស់លោកអ្នក ។

**ការិយាល័យ STREAM ប្រចាំប្រទេសកម្ពុជាមានអាស័យដ្ឋានដូចខាងក្រោម :**

ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ (នាយកដ្ឋានជលផល)
អាគារលេខ ១៨៦ វិថី ព្រះនរោត្តម ខ័ណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទលេខ : (៨៥៥ ២៣) ២១០ ១៥៤
ទូរសារលេខ : (៨៥៥ ២៣) ២១០ ១៥៤
អ៊ីមែល : **cfdo@online>com>kh**

**ការិយាល័យ STREAM ប្រចាំតំបន់ :**

អាគារ ណាកា (NACA) នាយកដ្ឋានជលផល
បរិវេណ សាកលវិទ្យាល័យកាសេតសាទ
ផ្លូវ ផាហូលយ៉ូស៊ីន សង្កាត់ បែងឃេន
ទីក្រុងបាងកក ១០៩០៣ ប្រទេសថៃឡង់
ទូរសព្ទលេខ : ៦៦២ ៥៦១ ១៧២៨/២៩
ទូរសារលេខ : ៦៦២ ៥៦១ ១៧២៧
អ៊ីមែល : **stream@enaca.org**
**STREAM** គេហទំព័រ : www.streaminitiative.org